EMBASSY OF JAPAN
IN CAMBODIA

# PRESS RELEASE

No. 08PR-26/EoJ 26 February 2026

## Japan Provides US$307,720 for Installation of Water Supply System, and Construction of Primary School Building

The Government of Japan will provide US$307,720 in total for two recipient organizations under the framework, *the Grant Assistance for Grassroots Human Security Projects ("KUSANONE")*. The Grant Contracts were signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representatives of two recipients respectively, to carry out the following projects.

1. 'The Project for the Installation of Water Supply System at 9 Villages in Kondieng Reay Commune, Svay Rieng Province' (US$134,969)
Recipient: Svay Rieng Water Utility
In this project, water supply system will be installed in Svay Teab District, Svay Rieng Province. Currently, most of the people living in this area have difficulty accessing to safe drinking water and are facing health risks due to the lack of safe water supply facility within the commune. Through this project, more than 12,000 people will gain access to affordable clean water and adequate sanitation in the next three years, which will contribute to the improvement in their living standards.

2. 'The Project for the Construction of Samdach Krom Preah Primary School Building in Stung Treng Province' (US$172,751)
Recipient: Stung Treng Provincial Department of Education, Youth and Sport
In this project, a six-room school building equipped with school furniture, and a five-room toilet will be built at Samdach Krom Preah Primary School in Stung Treng City, Stung Treng Province. Currently, students at this school have difficulties in studying because the wooden school building and wooden furniture are in poor conditions. And there is less hygienic environment due to the lack of enough number of toilets. This project aims to bring about a safer and more comfortable learning environment, and it is expected to benefit around 580

students and 20 teachers.

Japan's "KUSANONE" Projects started in Cambodia in 1991 in order to support Cambodia's reconstruction and development at the grassroots level. The assistance aims to protect those who are vulnerable due to various factors such as poverty and/or misfortunes that directly threaten their lives, livelihood, and dignity, as well as to promote self-reliance of local communities. Since 1991, the Government of Japan has provided over US$72 million for mainly local authorities and non-governmental organizations to implement over 700 KUSANONE projects throughout Cambodia.

---

*Embassy of Japan in Cambodia*
*Tel: 023-217-161*
*Email: eco.jpn@pp.mofa.go.jp*
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ក្នុងប្រទេសកម្ពុជា**
**សេចក្តីប្រកាសព័ត៌មាន**

លេខ. 08PR-26/EoJ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៦

**ជប៉ុនផ្តល់ថវិកា ៣០៧,៧២០ ដុល្លារអាមេរិក**
**សម្រាប់ការស្តារតម្លើងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងការសាងសង់អគារសាលាបឋមសិក្សា**

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន ៣០៧,៧២០ ដុល្លារអាមេរិក ដល់ស្ថាប័នទទួលជំនួយចំនួនពីរ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (គូសាណូណិ)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង តំណាងស្ថាប័នទទួលជំនួយចំនួនពីរសម្រាប់អនុវត្តគម្រោងដូចតទៅ។

**១. គម្រោងតម្លើងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅភូមិចំនួន៩ ក្នុងឃុំកណ្តៀងរាយ ខេត្តស្វាយរៀង (ថវិកាចំនួន ១៣៤,៩៦៩ ដុល្លារអាមេរិក)**

ស្ថាប័នទទួលជំនួយ៖ រដ្ឋាករទឹកខេត្តស្វាយរៀង

ក្នុងគម្រោងនេះ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនឹងត្រូវបានតម្លើងនៅស្រុកស្វាយទាប ខេត្តស្វាយរៀង។ បច្ចុប្បន្ន ប្រជាជនភាគច្រើនដែលរស់នៅក្នុងតំបន់នេះ មានភាពលំបាកក្នុងការទទួលបានទឹកដែលមានសុវត្ថិភាពសម្រាប់ទទួលទាន និងកំពុងប្រឈមនឹងហានិភ័យសុខភាព ដោយសារកង្វះការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងឃុំ។ តាមរយៈគម្រោងនេះ ក្នុងរយៈពេល ៣ឆ្នាំខាងមុខ ប្រជាជនជាង ១២,០០០នាក់ នឹងទទួលបានទឹកស្អាតដែលមានតម្លៃសមរម្យ និងអនាម័យគ្រប់គ្រាន់ ដែលនឹងរួមចំណែកក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ពួកគេ។

**២. គម្រោងសាងសង់អគារសាលាបឋមសិក្សាសម្តេចក្រុមព្រះ ក្នុងខេត្តស្ទឹងត្រែង (ថវិកាចំនួន ១៧២,៧៥១ ដុល្លារអាមេរិក)**

ស្ថាប័នទទួលជំនួយ៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង

ក្នុងគម្រោងនេះ អគារសិក្សា១ខ្នង ៦បន្ទប់ បំពាក់ដោយគ្រឿងសង្ហារឹម និងបង្គន់អនាម័យ១ខ្នង ៥បន្ទប់ នឹងត្រូវបានសាងសង់នៅសាលាបឋមសិក្សាសម្តេចក្រុមព្រះ ក្នុងក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។ បច្ចុប្បន្ន សិស្សនៅសាលានេះមានការលំបាកក្នុងការសិក្សា ដោយសារអគារសិក្សាឈើ និងគ្រឿងសង្ហារឹមធ្វើ

អំពីឈើ មានសភាពទ្រុឌទ្រោម។ ហើយបរិស្ថាននៅទីនោះមិនសូវមានអនាម័យទេ ដោយសារកង្វះខាតនូវចំនួនបង្គន់អនាម័យ។ គម្រោងនេះមានគោលបំណងនាំមកនូវបរិស្ថានសិក្សាដែលមានសុវត្ថិភាព និងផាសុកភាពជាងមុន ហើយយើងរំពឹងថាគម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់សិស្សចំនួន ៥៨០នាក់ និងគ្រូបង្រៀនចំនួន ២០នាក់។

គម្រោងគូសាណូណិរបស់ជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញ នៅតាមកម្រិតមូលដ្ឋាន។ ជំនួយឥតសំណងគូសាណូណិ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង/ឬ ភាពអកុសលនានា ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់អាយុជីវិត ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាលើកកម្ពស់ភាពមានម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៧២លាន ដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បី អនុវត្តគម្រោងគូសាណូណិជាង ៧០០គម្រោង នៅទូទាំងប្រទេសកម្ពុជា៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

សុន្ទរកថារបស់ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី**
ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៦

សូមគោរព

- **ឯកឧត្តម តន់ សុខជា** អគ្គនាយកនៃនាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- **ឯកឧត្តម ទេព ណារីន** អគ្គនាយកនៃរដ្ឋាករទឹកខេត្តស្វាយរៀង
- **លោក ហ៊ាង ប៉ូលី** ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្ទឹងត្រែង
- លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី។

អរុណសួស្តី និងសូមស្វាគមន៍មកកាន់ស្ថានទូតជប៉ុន។ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយនាថ្ងៃនេះ ដែលកំពុងត្រូវបានអនុវត្តតាមរយៈគ្រោងការណ៍ជំនួយឥតសំណងគូសាណូណិ សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។

ជាដំបូង សូមអនុញ្ញាតឱ្យខ្ញុំនិយាយដោយសង្ខេបអំពីជម្លោះព្រំដែនរវាងកម្ពុជានិងថៃ។ រដ្ឋាភិបាលជប៉ុន និងរូបខ្ញុំផ្ទាល់ ស្វាគមន៍ការសម្រេចបាននូវកិច្ចព្រមព្រៀងបទឈប់បាញ់លើកទី២ និងការវិលត្រឡប់មកវិញដោយសុវត្ថិភាពរបស់ទាហានកម្ពុជាទាំង១៨រូប នៅមុនដំណាច់ឆ្នាំកន្លងទៅ។ រដ្ឋាភិបាលជប៉ុននឹងបន្តផ្តួចផ្តើមការគាំទ្រនានា ដើម្បីកាត់បន្ថយភាពតានតឹងបន្ថែមទៀត ក៏ដូចជាផ្តល់នូវជំនួយផ្សេងៗ។

ខ្ញុំសុំត្រលប់មកនិយាយពីពិធីនាថ្ងៃនេះវិញ។ រដ្ឋាភិបាលជប៉ុនបាននិងកំពុងផ្តល់ជំនួយឥតសំណងគូសាណូណិនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩១ ដើម្បីជួយដោយផ្ទាល់ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលនានា ក្នុងការអនុវត្តគម្រោងរបស់ពួកគាត់។ គូសាណូណិ មានន័យថា "ឫសស្មៅ" ក្នុងភាសាជប៉ុន ហើយក្នុងរយៈពេលជាង៣០ឆ្នាំកន្លងមកនេះ ស្ថានទូតជប៉ុនបានអនុវត្តជាង ៧០០គម្រោង នៅទូទាំងប្រទេសកម្ពុជា តាមរយៈគ្រោងការណ៍ជំនួយឥតសំណងគូសាណូណិ។ យើងមានសេចក្តីសោមនស្សរីករាយដែលគម្រោងទាំងនេះ បានចូលរួមចំណែកដោយផ្ទាល់ក្នុងការលើកកម្ពស់គុណភាពជីវភាពរបស់ប្រជាជនកម្ពុជានៅកម្រិតមូលដ្ឋាន។

ខ្ញុំសូមណែនាំគម្រោង ដែលយើងបានចុះហត្ថលេខានាថ្ងៃនេះ។

សម្រាប់គម្រោងទី១ ដែលនឹងអនុវត្តដោយរដ្ឋាករទឹកខេត្តស្វាយរៀង រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ១៣៤,៩៦៩ ដុល្លារអាមេរិក (មួយរយសាមសិបបួនពាន់ប្រាំបួនរយហុកសិបប្រាំមួយដុល្លារ

អាមេរិក) ដើម្បីតម្លើងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងខេត្តស្វាយរៀង។ ក្នុងរយៈពេល ៣ឆ្នាំខាងមុខ គម្រោងនេះនឹងរួមចំណែកក្នុងការផ្គត់ផ្គង់ទឹកស្អាតដែលមានតម្លៃសមរម្យដល់ប្រជាជនជាង ១២,០០០នាក់ ក្នុងភូមិចំនួន៩។ គម្រោងនេះនឹងកែលម្អអនាម័យ ក៏ដូចជាលើកកម្ពស់គុណភាពជីវិតប្រជាជនក្នុងតំបន់គោលដៅ។

សម្រាប់គម្រោងទី២ ដែលនឹងអនុវត្តដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ១៧២,៧៥១ ដុល្លារអាមេរិក (មួយរយចិតសិបពីរពាន់ប្រាំពីររយហាសិបមួយដុល្លារអាមេរិក) សម្រាប់ការសាងសង់ និងបំពាក់គ្រឿងសង្ហារឹមអគារសិក្សាមួយខ្នងមានចំនួន ៦បន្ទប់ និងបង្គន់អនាម័យចំនួន ៥បន្ទប់។ បរិក្ខារសាលាថ្មីៗទាំងនេះ នឹងផ្តល់នូវបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព និងផាសុកភាពជាងមុន ដែលនឹងផ្តល់អត្ថប្រយោជន៍ដល់សិស្សសរុបប្រមាណ ៥៨០នាក់ និងគ្រូបង្រៀនចំនួន ២០នាក់។

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានសង្កេតឃើញការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជានាពេលថ្មីៗនេះ។ ទោះជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមជាច្រើន ដែលដែលត្រូវដោះស្រាយ ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន។ ក្រោមភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ជប៉ុននឹងបន្តចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ តាមរយៈគ្រោងការណ៍ជំនួយអភិវឌ្ឍន៍ផ្លូវការផ្សេងៗ រួមទាំង "គូសាណូណេ" ផងដែរ។

ជាចុងក្រោយ ខ្ញុំសូមជូនពរ ឯកឧត្តម លោក លោកស្រី ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ សុភមង្គល និងសូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណច្រើនសម្រាប់ការយកចិត្តទុកដាក់ស្តាប់។